# មហាព្រះវេស្សន្តរជាតក (សង្ខេប)

## កណ្ឌវនប្បវេសន៍ (ទី៤)

ព្រះបាទស្រីវេស្សន្តរបរវពុទ្ធវង្ស ទ្រង់យាងយាត្រាតាមមាគ៌ា ក្នុងពនាល័យក្សត្រថ្ងៃទ្រង់យាងបណ្ដើរសំណេះសំណាលបណ្ដើរ។ ចំណែកខាងកុមារទាំងពីរបានឃើញផ្លែឈើក្នុងពានីក៏យំទារ។ ដើមឈើទាំងសងខាងមាគ៌ាក៏ទន់ទោរបង្អោនផលាផលមកថ្វាយ។

ទេវតាទាំងឡាយ បានបង្រួញផ្លូវដើម្បីក្សត្រីទាំង៤ព្រះអង្គ យាងទៅតែមួយថ្ងៃដល់មាតុលនគរដែលបេតរដ្ឋមានចម្ងាយ៣០យោជន៍។ ពួកអ្នកចេតរាស្ត្រទាំងស្ដេចទាំងមន្ត្រីបានធ្វើបដិសណ្ឋារៈកិច្ច សាកសួរជ្រាបសេចក្ដីសព្វគ្រប់ប្រការមានក្ដីអាសូរករុណា ក៏ទ្រង់ព្រះកន្សែងថ្ងូងយោបំរង់រងោកគ្រប់ព្រះអង្គាបានព្រមព្រៀងគ្នាថ្វាយរាជសម្បត្តិចំពោះព្រះវេស្សន្តរ ដោយការអេះអាងគ្រប់ជំពូក។ តែព្រះវេស្សន្តរពុំព្រមទទួល។

ពួកស្ដេចចេតរាស្ត្រ កាលឃាត់ព្រះវេស្សន្តរពុំបាន ក៏មានព្រះភ័ក្ត្រដោកដាំដោយអស្សុធារា ពណ៌នារៀបរាប់នូវផ្លូវគួរជាទីទៅកាន់ភ្នំគិរីវង្កត ថ្វាយព្រះវេស្សន្តរទ្រង់ព្រះសណ្ដាប់ ហើយទ្រង់ចាត់ការ រៀបសេនាយោធាជូនព្រះរាជដំណើរចេញពីមាតុលនគរ ទៅទិសខាងជើងអស់ផ្លូវចម្ងាយ១៥យោជន៍ ដល់ភ្នំគិរីវង្កតទើប បណ្ដោយព្រះវេស្សន្តរ និងព្រះនាងមទ្រីនាំព្រះរាជបុត្រីបុត្រាលីលាទៅតាមផ្លូវច្រកភ្នំ ហើយចាត់កូនប្រុសអ្នកចេតរាស្ត្រម្នាក់ឈ្មោះចេតបុត្រ ជាថ្មើរព្រៃឲ្យនៅចាំនាច្រកភ្នំដើម្បីការពារកុំឲ្យមានសត្រូវណាបៀតបៀនព្រះវេស្សន្តរបាន ទើបនាំគ្នានិវត្តមកឋានមាតុលនគរវិញហោង។

ឯព្រះវេស្សន្តរពបាជាលី ព្រះនាងមទ្រីទ្រង់ពចៅក្រឹស្នា យាត្រាទៅតាមផ្លូវចុះតែជើងមនុស្សម្នាក់អស់ទីចម្ងាយ១៥យោជន៍ទៀត ទើបដល់ឆ្នេរស្រះបោក្ខរណី បានឃើញអាស្រមបទដែលសក្ក ទេវិន្ទឥន្ទកោសិយឲ្យវិស្សកម្មទៅបុត្រមកនិម្មិតថ្វាយ។ ព្រះអង្គចូល ដល់អាស្រមបទនោះ បានទតឃើញអក្ខរា ក៏ទ្រង់ជ្រាបថា ទីនេះទេវតានិម្មិតដើម្បីព្រះអង្គទើបទ្រង់ដោះផ្នូសរ ព្រះខ័ណថ្វាអំពីព្រះអង្សា ផ្លាស់អម្ពរពស្ត្រា ទ្រទ្រង់ស្បែកខ្លា ចងជដាមណ្ឌល

អត្ថបទដោយ៖ មាស សុភាព

តម្កល់ភេទជាមហាឥសី។ ឯសម្តេចព្រះភគវតីស្រីមទ្រី ក៏ទ្រង់នូវសំពត់សម្បកឈើដែលគេក្រងដោយស្បូវភ្លាំង ពានាធៀងស្មាដោយស្បែកខ្លាចងព្រះកេសាជាជដាមណ្ឌលតម្កល់ភេទជាតាបសិនីហើយ ទ្រង់បំបួសព្រះរាជបុត្រាបុត្រីដោយក្តីជ្រះថ្លា ចម្រើនមេត្តាភាវនា នៅក្នុងអាស្រមបទនាចង្អេះភ្នំគិរីវង្កតបព៌តជាទីរហោស្ថាន ឥតមានទុក្ខភ័យក្តីអន្តរាយឡើយហោង។

(ចប់ កណ្ឌទី៨ នៃបរិវេសន៍ សូមរង់ចាំតាមដានកណ្ឌទី៩ នៅសប្តាហ៍ក្រោយ)

អត្ថបទដោយ៖ មាស សុភាព